វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
Working Together for Positive Change

# ការពិនិត្យក្របខ័ណ្ឌច្បាប់និងគោលនយោបាយស្តីពីការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា

**សេចក្តីបញ្ជាក់៖** ទស្សនៈក្នុងរបាយការណ៍នេះគឺជាលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ទីប្រឹក្សាឯករាជ្យ ហើយវាមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាឡើយ។

## សេចក្តីសង្ខេប

ឯកសារសង្ខេបគោលនយោបាយនេះ ពិនិត្យក្របខ័ណ្ឌច្បាប់ និងគោលនយោបាយស្តីពីការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅប្រទេសកម្ពុជា និងពិនិត្យបទពិសោធន៍ល្អៗ ស្តីពីការចូលរួមរបស់សាធារណជននៅក្នុងប្រទេសឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន ជាប្រទេសពីរដែលទទួលបានពិន្ទុលើការចូលរួមជាសាធារណៈខ្ពស់ជាងគេក្នុងចំណោមបណ្តាប្រទេសក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ( អាស៊ាន) ទាំងអស់ដែលចូលរួមការស្ទង់មតិអង្កេតលើការផ្សព្វផ្សាយថវិកា (Open Budget Survey) ។ ការស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវដែលចែកចេញជា៣ដំណាក់កាលសំខាន់ៗ ដូចដែលបង្ហាញនៅក្នុងផ្នែកវិធីសាស្ត្រស្រាវជ្រាវនៅផ្នែកខាងចុងនៃអត្ថបទ។ ការសិក្សានេះរកឃើញថាច្បាប់ និងគោលនយោបាយរបស់ប្រទេសកម្ពុជាផ្តល់ឱកាសតិចតួចបំផុតសម្រាប់ការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ជាតិ។ ក្រៅពីច្បាប់ និងគោលនយោបាយទាំងនេះ យន្តការ និងនីតិវិធីជាលក្ខណៈប្រព័ន្ធ និងដែលអាចបង្ករភាពងាយស្រួលដល់ការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ជាតិ ក៏មានតិចតួចបំផុតដែរ។ ប៉ុន្តែនៅថ្នាក់ក្រោមជាតិមានច្បាប់ និងគោលនយោបាយជាច្រើនដែលត្រូវបានតាក់តែងឡើង ដើម្បីលើកកម្ពស់ការចូលរួមពីសាធារណជនជាពិសេសក្នុងការរៀបចំ និងការត្រួតពិនិត្យការអនុវត្តថវិកា។ បញ្ហាគឺនៅត្រង់ថា ការអនុវត្តច្បាប់ និងបទបញ្ញានៅថ្នាក់ក្រោមជាតិទាក់ទងនឹងការចូលរួមពីសាធារណជននៅទូទាំងប្រទេស គឺនៅតែមានការខ្វះខាតច្រើននៅឡើយ។ ហេតុដូច្នេះឯកសារសង្ខេបគោលនយោបាយនេះមានបំណងស្នើឡើងនូវអនុសាសន៍មួយចំនួន ដើម្បីកែលម្អការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## សេចក្តីផ្តើម

ការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាសិទ្ធិមួយហើយវាអាចជួយរួមចំណែកធ្វើឱ្យរដ្ឋាភិបាលកាន់តែមានតម្លាភាពនិងគណនេយ្យភាព ការផ្តល់សេវាសាធារណៈកាន់តែមានភាពល្អប្រសើរ និងបង្កើនទំនុកចិត្តពីប្រជាពលរដ្ឋនិងភាពស្របច្បាប់របស់រាជរដ្ឋាភិបាល។ ការចូលរួមជាសាធារណៈក្នុងវិស័យហិរញ្ញវត្ថុសាធារណៈនៅប្រទេសកម្ពុជាជាពិសេសនៅថ្នាក់ជាតិដែលក្នុងនោះរួមមានវដ្តថវិកាផងនៅមានកម្រិតទាបជាងនៅក្នុងបណ្តាប្រទេសមាជិកអាស៊ានភាគច្រើន។ ដូច្នេះដើម្បីឱ្យពិន្ទុនៃការចូលរួមជាសាធារណៈអាចកើនឡើងស្មើជាមួយនឹងពិន្ទុមធ្យមរបស់បណ្តាសមាជិកអាស៊ានទាំងអស់ ប្រទេសកម្ពុជាត្រូវបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួន។

### ពិន្ទុនៃការចូលរួមជាសាធារណៈរបស់ប្រទេសកម្ពុជាធៀបជាមួយពិន្ទុរបស់ប្រទេសក្នុងតំបន់ដទៃទៀត

***ប្រភព:*** *ចងក្រងដោយអ្នកនិពន្ធពីសន្ទស្សន៍អង្កេតលើការផ្សព្វផ្សាយថវិកា (Open Budget Index) និងការស្ទង់មតិអង្កេតលើការផ្សព្វផ្សាយថវិកា (Open Budget Surveys) របស់ប្រទេសកម្ពុជានិងសមាជិកអាស៊ានដទៃទៀត (២០១៥-២០១៧) ។*

***កំណត់ចំណាំ:*** *ខ្សោយ = ពិន្ទុ ០-៣៣, មធ្យម = ពិន្ទុ ៣៤-៦៦, ខ្ពស់ = ពិន្ទុ ៦៧-១០០*



ដើម្បីឱ្យការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានការរីកចម្រើន រាជរដ្ឋាភិបាលគួរចាប់ផ្តើមពីការកែទម្រង់ដោយធ្វើឱ្យមានក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដែលលើកកម្ពស់ការចូលរួមពីសាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានជាក់លាក់ និងគួរបង្កើតយន្តការដែលអាចប្រើប្រាស់បានសិន និងរៀបចំវាឱ្យមានលក្ខណៈជាប្រព័ន្ធនៅពេលក្រោយ។ ដូច្នេះការសិក្សានេះមានគោលបំណងចំបងពីរ (១) វិភាគក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធនឹងការចូលរួមជាសាធារណៈក្នុងកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលក្នុងនោះរួមមានដំណើរការធ្វើថវិកា និង (២) ឈានឆ្ពោះទៅរកច្រកចូលជាក់លាក់ដើម្បីឱ្យមានការចូលរួមពីសាធារណជនក្នុងដំណើរការរៀបចំផែនការ ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ការរកឃើញសំខាន់ៗ

១. ច្បាប់សំខាន់ៗរបស់ប្រទេសកម្ពុជារួមមានរដ្ឋធម្មនុញ្ញ និងច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ មិនមានចែងអំពីការចូលរួមរបស់សាធារណជន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទេ។ មិនតែប៉ុណ្ណោះ ទោះជាមានយន្តការដែលមានស្រាប់ដូចជាក្រុមការងារបច្ចេកទេស (TWG) សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏ដោយ ក៏ការចូលរួមរបស់សាធារណជននៅមានកម្រិតស្តួចស្តើងនិងគុណភាពនៅទាបនៅឡើយ ។

២. បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភាមានចែងពីការពិគ្រោះយោបល់ជាសាធារណៈ ក៏ប៉ុន្តែនៅខ្វះនីតិវិធីលម្អិត និងយន្តការជាក់លាក់ដើម្បីឱ្យសាធារណជន និងអង្គការសង្គមស៊ីវិលចូលរួមការពិគ្រោះយោបល់ឱ្យមានប្រសិទ្ធភាព។ ហេតុដូច្នេះទោះជាស្ថាប័នទាំងពីរនេះផ្តល់ឱកាសឱ្យសាធារណជន និងអង្គការសង្គមស៊ីវិលចូលរួមក្នុងការងារខ្លួនក៏ដោយ ក៏គុណភាពនៃការចូលរួមជាក់ស្តែងនៅមានកម្រិតទាប។

៣.ច្បាប់ស្តីពីសវនកម្ម មិនមានចែងអំពីការចូលរួមរបស់សាធារណជនទេ។ ស្តង់ដារសវនកម្មសាធារណៈ(ឆ្នាំ២០១១) អនុញ្ញាតឱ្យអាជ្ញាធរសវនកម្មជាតិសហការស្របច្បាប់ជាមួយវិទ្យាស្ថានស្រាវជ្រាវជាន់ខ្ពស់ និងអង្គភាពវិជ្ជាជីវៈដែលជាផ្នែកមួយនៃអង្គការសង្គមស៊ីវិលក្នុងដំណើរការសវនកម្ម ប៉ុន្តែមិនបានចែងពីការចូលរួមរបស់អង្គការសង្គមស៊ីវិលទូទៅនោះទេ។ ក្រៅពីនេះស្ទើរតែគ្មានយន្តការ ឬឧបករណ៍គោលនយោបាយអចិន្ត្រៃយ៍ដែលបង្កើតឡើងសម្រាប់ ឬដោយអាជ្ញាធរសវនកម្មជាតិដើម្បីអញ្ជើញប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលឱ្យដាក់ពាក្យបណ្តឹង ផ្តល់នូវធាតុចូលទៅក្នុងកម្មវិធីសវនកម្មនិងការស៊ើបអង្កេតរបស់ខ្លួន និងដើម្បីឱ្យអាជ្ញាធរសវនកម្មជាតិខ្លួនឯងអាចផ្តល់មតិយោបល់ត្រលប់ទៅលើធាតុចូលរបស់ប្រជាពលរដ្ឋ និងសង្គមស៊ីវិលនោះទេ។

៤ . ច្បាប់និងគោលនយោបាយស្តីពីរដ្ឋបាលថ្នាក់ក្រោមជាតិមានចែងច្រើនចំណុចពីការចូលរួមរបស់សាធារណជនជាពិសេសទាក់ទងនឹងការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាន កម្មវិធីវិនិយោគសំណើគម្រោងថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋខ្លះៗក្នុងការតាមដានការអនុវត្ត ការត្រួតពិនិត្យនិងវាយតម្លៃ (M & E)។ ប៉ុន្តែ ការអនុវត្តច្បាប់និងគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានភាពអំណោយផលសម្រាប់ការចូលរួមទាំងនោះនៅមានភាពយឺតយ៉ាវ ជាក់ស្តែងនៅតំបន់មួយចំនួនតូច មានការចូលរួមច្រើនគួរឱ្យកត់សម្គាល់ រីឯតំបន់ភាគច្រើនស្ទើរតែគ្មានការចូលរួមសោះឬចូលរួមតិចតួចក៏មាន។

## អនុសាសន៍

### តើស្ថាប័ននីតិប្រតិបត្តិអាចបង្កើនការចូលរួមជាសាធារណៈបានតាមរបៀបណា?

១. ខណៈដែលរដ្ឋាភិបាលកំពុងរៀបចំផែនការវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈអោយបានមុនឆ្នាំ២០២០ គួរធានាថាវិសោធនកម្មនេះមានចែងពីការចូលរួមជាសាធារណៈយ៉ាងហោចណាស់ក្នុងវដ្តថវិកាទាំងមូល។ ប្រទេសហ្វីលីពីន គឺជាឧទាហរណ៍ដ៏ល្អឥតខ្ចោះមួយដែលប្រទេសនេះបានទទួលពិន្ទុពេញ ឬលើមធ្យម ក្នុងការស្ទង់មតិ អង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា Open Budget Survey សម្រាប់ការចូលរួមជាសាធារណៈដោយសារច្បាប់ និងគោលនយោបាយនានារបស់ប្រទេសនេះមានបទបញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ ហើយបទបញ្ញត្តិទាំងនេះត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋសភា និងព្រឹទ្ធសភា គឺជាតួអង្គយ៉ាងសំខាន់ក្នុងការអនុវត្តគំនិតផ្តួចផ្តើមវិសោធនកម្មច្បាប់នេះ។

២. ការចូលរួមជាសាធារណៈរបស់ប្រទេសកម្ពុជានឹងអាចទទួលបានអត្ថប្រយោជន៍ពីការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដូចដែលបានកើតឡើងនៅក្នុងប្រទេសឥណ្ឌូនេស៊ី។ ទីស្តីការគណៈរដ្ឋមន្ត្រីគួរធ្វើចំណាត់ការបន្តទៀតដើម្បីឈានដល់ការអនុម័តនិងអនុវត្តច្បាប់នេះ។

៣. នៅថ្នាក់ក្រោមជាតិប្រជាពលរដ្ឋនិងអង្គការសង្គមស៊ីវិលមានលំហច្បាប់និងគោលនយោបាយរួចជាស្រេច ក្នុងការចូលរួមក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ ការរៀបចំថវិកា និងការត្រួតពិនិត្យ និងការវាយតម្លៃ (M&E) ។ ការអនុវត្តច្បាប់ និងគោលនយោបាយដែលមានការចូលរួមបែបនេះជាបណ្តើរៗបានធ្វើឡើងនៅក្នុងឃុំ និងសង្កាត់មួយចំនួន ដែលមានគម្រោងរបស់ក្រសួងមហាផ្ទៃ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន។ ឃុំផ្សេងៗទៀតនៅទូទាំងប្រទេសគួរអនុវត្តតាមគំរូល្អដែលមានស្រាប់ទាំងនេះ។ ចំណុចសំខាន់បំផុតគឺការធានានូវការអនុវត្តច្បាប់និងគោលនយោបាយថ្នាក់ក្រោមជាតិដែលមានចែងអំពីការចូលរួមជាសាធារណៈរួចហើយឱ្យបានខ្ជាប់ខ្ជួន។

ខណៈដែលមានការយល់ស្របគ្នាថាវិសោធនកម្មច្បាប់ត្រូវការពេលវេលាច្រើននៅក្នុងដំណាក់កាលនេះ ជំហានដែលអាចធ្វើទៅបានដែលអាចជួយបង្កើនពិន្ទុការចូលរួមជាសាធារណៈក្នុងរយៈពេលខ្លីទៅមធ្យម គឺការពង្រឹងនិងពង្រីកយន្តការនានាដែលមានស្រាប់។ ប្រទេសឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីនបានប្រើប្រាស់យន្តការស្រដៀងនេះដើម្បីបង្កើនការចូលរួមជាសាធារណៈរបស់ខ្លួន។ ខាងក្រោមនេះ គឺជាវិធានការដែលអាចហុចផលបានភ្លាមៗ។

រឿងដ៏ជាក់លាក់មួយ គឺថាមានការចូលរួមខ្លះៗមកហើយពីសាធារណជនក្នុងការរៀបចំផែនការវិនិយោគឃុំ និង ថវិកាឃុំប្រចាំឆ្នាំ នៅតាមតំបន់មួយចំនួន។ ប៉ុន្តែគុណភាពនៃការចូលរួមជាសាធារណៈមានការខ្វះខាតខ្លះដោយសារតែដំណើរការធ្វើផែនការវិនិយោគឃុំ និងថវិកាឃុំត្រូវបានអនុវត្តដាច់ដោយឡែកពីគ្នាក្នុងករណីជាច្រើន។ ដូច្នេះគួរមានការចេញប្រកាសរួមរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីគោលការណ៍ណែនាំ និងនីតិវិធីក្នុងការសម្រួលការចូលរួមជាសាធារណៈក្នុងកិច្ចការថវិកាថ្នាក់ក្រោមជាតិ និងការរៀបចំផែនការវិនិយោគឃុំសង្កាត់។

៤និង៥.មេរៀនមួយដែលថ្នាក់ជាតិអាចរៀនសូត្រពីថ្នាក់ក្រោមជាតិដូចដែលបានពិភាក្សានៅក្នុងអនុសាសន៍ទី៣ ខាងលើគឺការប្រើប្រាស់ក្រុមការងារបច្ចេកទេសតាមក្រសួងនានា និង/អនុក្រុមការងារបច្ចេកទេសតាមអនុវិស័យ និងក្រុមការងារបច្ចេកទេសថ្នាក់ខេត្តជាយន្តការដើម្បីពង្រឹងនិងពង្រីកការចូលរួមជាសាធារណៈក្នុងដំណើរការថវិកា។ ខាងក្រោមនេះ គឺជាគំនិតពីរដែលអាចគួរពិចារណា៖

ទី១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចជម្រុញការចូលរួមយ៉ាងសកម្មរបស់តំណាងប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមវដ្តថវិកាទាំងមូល និងលើសពីនេះតាមរយៈការប្រើប្រាស់ ក្រុមការងារបច្ចេកទេសសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានស្រាប់ ឬយន្តការផ្សេងទៀតដែលសមស្របទៅនឹងគោលបំណងនេះ។ ជាការអនុវត្តជាក់ស្តែង តួនាទីរបស់ក្រុមការងារបច្ចេកទេសសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានស្រាប់នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺសម្រាប់តែគាំទ្រដល់ការរៀបចំថវិកា និងមិនមែនសម្រាប់ការពិភាក្សាលើបញ្ហាថវិកា និងការសម្រេចចិត្តលើបញ្ហានេះទេ។

ទោះបីជាយ៉ាងណាក៏ដោយជាមួយនឹងការចូលរួមរបស់តំណាងសាធារណជន និងអង្គការសង្គមស៊ីវិល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដឹងឮពីកង្វល់និងអាទិភាពរបស់ពួកគេ ដែលអាចយកទៅប្រើសម្រាប់ការកំណត់អាទិភាពថវិកាប្រចាំឆ្នាំ។ លើសពីនេះទៀត មេរៀនដែលទទួលបានពីការចូលរួមរបស់តំណាងសាធារណជន និងអង្គការសង្គមស៊ីវិលនៅក្នុងក្រុមការងារបច្ចេកទេសនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការរៀបចំថវិកាអាចត្រូវបានពង្រីក ដើម្បីជម្រុញការចូលរួមរបស់សាធារណជននៅក្នុងផ្នែកផ្សេងទៀតនៃវិស័យហិរញ្ញវត្ថុសាធារណៈ ដូចជាការត្រួតពិនិត្យការអនុវត្តថវិកា និងការផ្តល់មតិត្រលប់ជាដើម។ ក្នុងប្រការដែលថា យន្តការក្រុមការងារបច្ចេកទេស សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនមែនជាយន្តការសមស្របក្រសួងអាចអាចប្រើប្រាស់ឬពង្រឹងបន្ថែមយន្តការដែលមានស្រាប់រួចហើយ ឬគួរបង្កើតនូវយន្តការសមស្របថ្មីផ្សេងទៀត ដើម្បីគាំទ្រគំនិតផ្តួចផ្តើមនៃការចូលរួមជាសាធារណៈនេះ។ ដើម្បីសម្រេចគោលដៅទាំងនេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចចេញជាប្រកាសឬការជូនដំណឹងអំពីគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈក្នុងការរៀបចំថវិកា និងការត្រួតពិនិត្យ ការអនុវត្តថវិកា។

ទី២ អង្គការសង្គមស៊ីវិលអាចចូលរួមជាមួយក្រសួងពាក់ព័ន្ធនានានិងមន្ទីរជំនាញថ្នាក់ខេត្ត តាមរយៈយន្តការដែលមានស្រាប់។ ជាកាលានុវត្តភាពល្អមួយ នៅតាមក្រសួងពាក់ព័ន្ធនិងមន្ទីរជំនាញ ថ្នាក់ខេត្ត ដែលអនុវត្ត ថវិកាកម្មវិធី ក្រុមការងារបច្ចេកទេសតាមក្រសួងនានា និងអនុក្រុមការងារបច្ចេកទេសតាមអនុវិស័យនៃក្រសួងសាមី និងក្រុមការងារបច្ចេកទេសរបស់មន្ទីរជំនាញនៅថ្នាក់ខេត្ត និង/ឬយន្តការសមស្របដទៃទៀតបាននឹងកំពុងដំណើរការជាស្រេច។

ជាមួយនឹងយន្តការដែលមានស្រាប់នេះ សាធារណជន និងអង្គការសង្គមស៊ីវិល អាចចូលរួមជាមួយក្រសួង និងមន្ទីរបច្ចេកទេសពាក់ព័ន្ធនៅតាមខេត្ត ដើម្បីចូលរួមចំណែកក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាឧទាហរណ៍លើការចាត់អាទិភាពថវិកាតាំងពីដើមឡើយមក ជាពិសេសសម្រាប់វិស័យ ឬក្រសួងអាទិភាពមួយចំនួន។

អំណោះតទៅមុខរាជរដ្ឋាភិបាលក្រោមការផ្តួចផ្តើមគំនិតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញអនុក្រឹត្យមួយស្តីពីគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈក្នុងការរៀបចំថវិកា និងការតាមដានការអនុវត្តការចំណាយថវិការបស់ក្រសួងនានា ហើយសាកល្បងគំនិតថ្មីនេះជាមួយក្រសួងអាទិភាពមួយចំនួន ដូចជាក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាលជាដើម។ ក្នុងអនុក្រឹត្យនេះ ក្រសួងក៏អាចពិចារណាបញ្ចូលការចូលរួមរបស់តំណាងសាធារណជន និងអង្គការសង្គមស៊ីវិលថ្នាក់ខេត្តក្នុងការរៀបចំនិងការត្រួតពិនិត្យការអនុវត្តថវិការបស់មន្ទីរពាក់ព័ន្ធនានាផងដែរ។

## តើស្ថាប័ននីតិប្បញ្ញត្តិអាចបង្កើនការចូលរួមជាសាធារណៈបានតាមរបៀបណា?

អង្គនីតិបញ្ញត្តិនៅប្រទេសកម្ពុជាអាចប្រើប្រាស់សវនាការជាសាធារណៈដូចដែលបានអនុវត្តនៅក្នុងប្រទេសហ្វីលីពីន និងក្នុងកម្រិតណាមួយនៅប្រទេសឥណ្ឌូណេស៊ី ដែលជាមធ្យោបាយដ៏មានសក្តានុពលក្នុងការបង្កើនការចូលរួមជាសាធារណៈ។ ក្នុង

ករណីសំណើថវិកាប្រចាំឆ្នាំ រដ្ឋសភានិងព្រឹទ្ធសភា អាចពិចារណាពិភាក្សាជាមួយអង្គការសង្គមស៊ីវិល និងតំណាងសាធារណជនយ៉ាងសកម្ម និងមានលក្ខណៈជាប្រព័ន្ធមុនពេលសេចក្តីព្រាងច្បាប់ថវិកាជាតិត្រូវបានបញ្ជូនមកដល់ស្ថាប័នខ្លួន ដូចដែលបានអនុវត្តនៅប្រទេសហ្វីលីពីនក៏បាន។ បទបញ្ជាផ្ទៃក្នុងរដ្ឋសភានិងព្រឹទ្ធសភាអាចត្រូវកែសម្រួលឡើងវិញដើម្បីបញ្ចូលគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈក្នុងសវនាការរបស់ស្ថាប័ន និងយន្តការផ្តល់មតិយោបល់ដល់សាធារណជននិងសង្គមស៊ីវិល។

### តើអាជ្ញាធរសវនកម្មជាតិអាចបង្កើនការចូលរួមជាសាធារណៈបានតាមរបៀបណា?

វាជារឿងគួរឱ្យសាទរដែលអាជ្ញាធរសវនកម្មជាតិបាននិងកំពុងកែលម្អគេហទំព័ររបស់ខ្លួន។ មិនតែប៉ុណ្ណោះមាត្រា២៩នៃច្បាប់ស្តីពីសវនកម្មចែងថារបាយការណ៍សវនកម្មត្រូវចាត់ទុកថា "ជាឯកសារសាធារណៈ"។ ប៉ុន្តែគិតមកត្រឹមពេលនេះ អាជ្ញាធរសវនកម្មជាតិនៅមិនទាន់បានផ្សព្វផ្សាយឯកសារទាំងនេះជាសាធារណៈនៅឡើយទេ។ អាជ្ញាធរសវនកម្មជាតិគួរផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ទាំងនេះដើម្បីសម្រួល និងលើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈឱ្យកាន់តែទូលំទូលាយនិងកាន់តែស៊ីជម្រៅ។ បន្តទៅមុខទៀតក្នុងរយៈពេលខ្លីទៅមធ្យម អាជ្ញាធរសវនកម្មជាតិ គួរខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីពង្រឹងមធ្យោបាយទំនាក់ទំនងដែលនឹងជួយលើកកម្ពស់ទំនាក់ទំនងរបស់ស្ថាប័ននេះជាមួយសាធារណជននិងអង្គការសង្គមស៊ីវិល។ ការធ្វើបែបនេះ គឺដើម្បីឱ្យអាជ្ញាធរនេះទទួលបានធាតុចូលសម្រាប់កម្មវិធីសវនកម្មរបស់ខ្លួននិងអាចផ្តល់មតិយោបល់ត្រលប់ចំពោះធាតុចូលដល់សាធារណជនវិញ។ ក្នុងរយៈពេលវែង អាជ្ញាធរសវនកម្មជាតិអាចចេញ គោលការណ៍ណែនាំមួយដែលអាចឱ្យសាធារណជននិងអង្គការសង្គមស៊ីវិលចូលរួមក្នុងសវនកម្មសម្ចតិកម្ម ការងាររបស់ខ្លួន ហើយការងារនេះអាចចាប់ផ្តើមជាគម្រោងសាកល្បងមួយលើវិស័យអាទិភាពណាមួយ ដូចជាវិស័យអប់រំ ឬសុខាភិបាលជាដើម។

### តើស្ថាប័ននីតិប្រតិបត្តិស្ថាប័ននីតិប្បញ្ញត្តិនិងអាជ្ញាធរសវនកម្មជាតិអាចប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍តាមបែបព័ត៌មានវិទ្យា(ICT) ដើម្បីបង្កើនការចូលរួមជាសាធារណៈបានតាមរបៀបណា?

ស្ថាប័នរដ្ឋស្ទើរតែទាំងអស់នៅប្រទេសកម្ពុជា មានគេហទំព័រ និងគណនីហ្វេសប៊ុកផ្ទាល់ខ្លួន។ ហេតុដូច្នេះ ក្រសួងសាម៉ីនានា រដ្ឋសភា និងព្រឹទ្ធសភា និងអាជ្ញាធរសវនកម្មជាតិអាចទាញផលប្រយោជន៍ពីការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍តាមបែបព័ត៌មានវិទ្យា (ICT) ដែលមានប្រសិទ្ធភាព និងចំណាយទាបនានាបែបនេះដើម្បីឱ្យមានការចូលរួមពីសំណាក់សាធារណជន និងអង្គការសង្គមស៊ីវិលក្នុងកិច្ចការរបស់ពួកគេនៅដំណាក់កាលនានានៃវដ្តថវិកា ក៏ដូចជាការរៀបចំ និងអនុវត្តផែនការ ឬយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការផ្តល់សេវា របស់ខ្លួន។ គ្រប់ស្ថាប័នដែលពាក់ព័ន្ធគួរកសាងសមត្ថភាពបុគ្គលិករបស់ពួកគេជាពិសេសលើជំនាញលើកកម្ពស់តម្លាភាព និងគណនេយ្យភាពថវិកាការចូលរួមជាសាធារណៈក្នុងការធ្វើថវិកា ទំនាក់ទំនងសាធារណៈ និងការប្រើប្រាស់ និងថែរក្សាឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា។ ស្ថាប័នទាំងនេះអាចស្វែងរកការគាំទ្រពីអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ប្រសិនបើធនធានខាងក្នុងរបស់ខ្លួនមិនមានគ្រប់គ្រាន់។

## វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះធ្វើឡើងជាបីដំណាក់កាល។ ដំណាក់កាលទី១ គឺការពិនិត្យក្របខ័ណ្ឌច្បាប់ និងគោលនយោបាយស្តីពីការចូលរួមរបស់សាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅប្រទេសកម្ពុជា និងការពិនិត្យបទពិសោធន៍របស់ប្រទេសឥណ្ឌូនេស៊ីនិងប្រទេសហ្វីលីពីន។ ដំណាក់កាលទី២ គឺកិច្ចប្រជុំពិគ្រោះយោបល់ជាមួយស្ថាប័នរដ្ឋចំនួន៣ ដែលធ្វើការទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ដំណាក់កាលទី៣គឺកិច្ចសម្ភាសន៍ជាមួយអ្នកជំនាញ និងអ្នកអនុវត្តផ្ទាល់មួយចំនួនដែលធ្វើការក្នុងវិស័យពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅឃុំមួយនៅខេត្តកណ្តាល។ ការស្រាវជ្រាវនេះធ្វើឡើងដោយផ្អែកលើទស្សនទាន "ការចូលរួមដោយការអញ្ជើញ" "invited participation" ដើម្បីធ្វើការវិភាគ។ទស្សនទាននេះត្រូវបានបង្កើតឡើងដោយគម្រោងគំនិតផ្តួចផ្តើមសកលដើម្បីតម្លាភាពសារពើពន្ធ (GIFT)។ "ការចូលរួមដោយការអញ្ជើញ" មានន័យថាការចូលរួមដែលផ្តួចផ្តើមឡើងដោយស្ថាប័នរដ្ឋដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រសួងសាម៉ី ឬរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីស្វែងរកធាតុចូលពីសាធារណជនក្នុងពេលរៀបចំធ្វើថវិកា និងក្នុងដំណើរការធ្វើថវិកាផ្សេងទៀត។ ស្ថាប័នរដ្ឋក៏អាចផ្តល់យោបល់ត្រលប់ទៅលើមតិយោបល់ និងធាតុចូលរបស់សាធារណជនតាមរយៈការចូលរួមបែបនេះផងដែរ។


វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
Working Together for Positive Change

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
អាសយដ្ឋានៈ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ប្រអប់សំបុត្រ ២២៩៥ ភ្នំពេញ-៣ កម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខៈ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែលៈ info@ngoforum.org.kh
គេហទំព័រៈ www.ngoforum.org.kh